រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ: ៤៣២ សរ៉ាំ៣

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# សេចក្ដីជូនដំណឹង
## ស្ដីពី
## ការបំពេញកាតព្វកិច្ចតាមការកំណត់ដោយ ច្បាប់ស្ដីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល

ក្រសួងមហាផ្ទៃ មានកិត្តិយសសូមជម្រាបជូនដំណឹងដល់សមាគមនិងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ព្រមទាំងសាធារណជនជាតិនិងអន្តរជាតិ មេត្តាជ្រាបថា នាពេលកន្លងមក ក្រសួងមហាផ្ទៃបានដាក់ចេញនូវសេចក្ដីជូនដំណឹងរំលឹកអំពីការបំពេញកាតព្វកិច្ចរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកជាបន្តបន្ទាប់ចំនួន៣លើករួចមកហើយ និងបានកត់សម្គាល់ឃើញថា សមាគមនិងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយចំនួនបានមកបំពេញកាតព្វកិច្ចបានត្រឹមត្រូវ ប៉ុន្តែមួយចំនួនទៀតនៅតែបន្តខកខានពុំបានមកបំពេញកាតព្វកិច្ចស្របតាមបទប្បញ្ញត្តិនៃច្បាប់ស្ដីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងលិខិតបទដ្ឋានគតិយុត្តនានាជាធរមាននៅឡើយ។ ក្នុងន័យនេះ ក្រសួងមហាផ្ទៃសូមធ្វើការក្រើនរំលឹកសារជាថ្មី (លើកទី៤) ដល់សមាគមនិងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកថា ដើម្បីធានាបាននូវការអនុវត្តសកម្មភាពប្រតិបត្តិការការងារត្រឹមត្រូវតាមគោលការណ៍ច្បាប់កំណត់ និងការពារបាននូវផលប្រយោជន៍ស្របច្បាប់របស់ខ្លួន និងផលប្រយោជន៍សាធារណៈ ព្រមទាំងចូលរួមលើកកម្ពស់កិច្ចសហប្រតិបត្តិការក្នុងភាពជាដៃគូរវាងសមាគមនិងអង្គការមិនមែនរដ្ឋាភិបាលជាមួយអាជ្ញាធរសាធារណៈប្រកបដោយតម្លាភាពនិងគណនេយ្យភាព សមាគមនិងអង្គការមិនមែនរដ្ឋាភិបាលទាំងអស់ត្រូវបំពេញកាតព្វកិច្ច ដូចខាងក្រោម៖

១-សមាគមនិងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីព័ត៌មានរាល់គណនី ដែលបានបើកសម្រាប់កិច្ចប្រតិបត្តិការរបស់ខ្លួននៅធនាគារក្នុងព្រះរាជាណាចក្រកម្ពុជាមកក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងរយៈពេលយ៉ាងយូរ៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃចុះបញ្ជី។ ចំពោះសមាគមនិងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលខកខានក្នុងការជូនដំណឹងនាពេលកន្លងមក **ត្រូវជូនដំណឹងមកក្រសួងមហាផ្ទៃ ឱ្យបានមុនដំណាច់ខែមីនា ឆ្នាំ២០២៥ ជាកំហិត។**

២-អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ត្រូវផ្ញើមកក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នូវរបាយការណ៍បូកសរុបសកម្មភាពការងារ និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំមួយច្បាប់ មិនឱ្យហួស**ពីដំណាច់ខែកុម្ភៈ ឆ្នាំ២០២៥។** ក្នុងករណីដែលទទួលបានការគាំទ្រហិរញ្ញវត្ថុពីម្ចាស់ជំនួយ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនោះត្រូវផ្ញើរបាយការណ៍ខាងលើ ដោយចម្លងចេញពីឯកសារដើមដែលផ្ញើទៅម្ចាស់ជំនួយ ក្នុងអំឡុងពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃផ្ញើទៅម្ចាស់ជំនួយ **ព្រមទាំងឯកសារគម្រោងកម្មវិធីការងារ និងកិច្ចព្រមព្រៀងហិរញ្ញប្បទាន១(មួយ)ច្បាប់ ដែលម្ចាស់ជំនួយបានយល់ព្រម** ដោយចម្លងពីឯកសារ



ទីស្ដីការក្រសួងមហាផ្ទៃ លេខ ២៧៥ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣៧២៦០៥២-២៣៧២៦០៥៣
ទូរសារ (៨៥៥) ២៣៧២៦០៥២-២៣៧២៦០៥៣ e-mail: moi@interior.gov.kh web: www.interior.gov.kh

ដើមឱ្យបានក្នុងអំឡុងពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃម្ចាស់ជំនួយបានឯកភាពយល់ព្រម។ របាយការណ៍នេះត្រូវតម្កល់ទុកនៅទីស្នាក់ការកណ្តាលរបស់ខ្លួនរយៈពេលយ៉ាងតិច៥(ប្រាំ)ឆ្នាំ។

៣-ក្នុងករណីមានការធ្វើវិសោធនកម្មលក្ខន្តិកៈ ឬការផ្លាស់ប្តូរទីស្នាក់ការ ឬការផ្លាស់ប្តូរតំណែងប្រធាន ឬតំណែងនាយកប្រតិបត្តិ ឬការប្រែប្រួលព័ត៌មានគណនីធនាគារ សមាគមនិងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងមហាផ្ទៃ ក្នុងរយៈពេលយ៉ាងយូរ១៥ (ដប់ប្រាំ)ថ្ងៃ គិតចាប់ពីថ្ងៃដែលផ្លាស់ប្តូរ ឬប្រែប្រួល ដោយភ្ជាប់មកជាមួយនូវសំណុំលិខិតដែលបានផ្លាស់ប្តូរ។

៤-សមាគមនិងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក មិនត្រូវធ្វើសកម្មភាពទាំងឡាយណាដែលផ្ទុយនឹងលក្ខន្តិកៈដែលបានតម្កល់ទុកនៅក្រសួងមហាផ្ទៃ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាជាធរមាន។

៥-សមាគមនិងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ពុំត្រូវបានអនុញ្ញាតឱ្យធ្វើសកម្មភាពណាមួយដែលមានគោលដៅស្វែងរកប្រាក់ចំណេញបម្រើផលប្រយោជន៍ផ្ទាល់ខ្លួន ឬយកកម្រៃមកចែកគ្នា ឬអាចធ្វើឱ្យប៉ះពាល់ដល់សន្តិសុខ ស្ថិរភាព និងសណ្តាប់ធ្នាប់សាធារណៈ ឬបង្កនូវភាពអន្តរាយដល់សន្តិសុខជាតិ ឯកភាពជាតិ វប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ល្អរបស់សង្គមជាតិកម្ពុជា ដែលប្រព្រឹត្តផ្ទុយនឹងបទប្បញ្ញត្តិនៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមានឡើយ។ ទន្ទឹមនេះ ត្រូវបានលើកទឹកចិត្តឱ្យសហការក្នុងភាពជាដៃគូជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ច និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងពេលធ្វើសកម្មភាពលើវិស័យជំនាញនីមួយៗស្របតាមច្បាប់កំណត់។

ក្រសួងមហាផ្ទៃ សង្ឃឹមនិងជឿជាក់យ៉ាងមុតមាំថា សមាគមនិងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកទាំងអស់ដែលបានចុះបញ្ជី និងតម្កល់សំណុំលិខិតលក្ខន្តិកៈនៅក្រសួងមហាផ្ទៃ ចូលរួមអនុវត្តតាមសេចក្តីជូនដំណឹងនេះ ប្រកបដោយការទទួលខុសត្រូវខ្ពស់ ក្នុងស្មារតីលើកកម្ពស់លទ្ធិប្រជាធិបតេយ្យ ពង្រឹងនីតិរដ្ឋនៅព្រះរាជាណាចក្រកម្ពុជា។

ថ្ងៃ.................ខែ.......... ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែតុលា..... ឆ្នាំ២០២៥

**ក្រសួងមហាផ្ទៃ**